# ១៨–ប្រកាសរួមរវាងទីស្តីការគណៈរដ្ឋមន្ត្រី
# និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពី
# ការអនុញ្ញាតអោយភ្ញៀវទេសចរបរទេសចូលទស្សនា
# រមណីយដ្ឋានអង្គរដោយឥតបង់ថ្លៃ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

លេខ : ៧៤ ទ.ក

**ប្រកាសរួមរវាងទីស្តីការគណៈរដ្ឋមន្ត្រី និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ស្តីពីការអនុញ្ញាតឱ្យ**

**ភ្ញៀវទេសចរបរទេស ចេញ-ចូល ទស្សនារមណីយដ្ឋានអង្គរដោយឥតបង់ថ្លៃ**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ០១ នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌជាតិ
- បានឃើញព្រះរាជក្រមលេខ ០១.នស. ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៩

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរ កែសំរួលដោយព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩
- បានឃើញកិច្ចសន្យាសម្បទានចុះហត្ថលេខាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០០ រវាងអាជ្ញាធរអប្សរា និង ក្រុមហ៊ុនសុខាអូតែល

## សំរេច

**ប្រការ១ :** អនុលោមតាមកិច្ចសន្យាសម្បទានដែលបានចុះហត្ថលេខាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០០ រវាងអាជ្ញាធរអប្សរាជាមួយនិងក្រុមហ៊ុនសុខាអូតែល ស្តីពីការកំរិតកូតាត្រឹមចំនួន ៣០០០ នាក់ថ្ងៃក្នុងមួយឆ្នាំ ការគ្រប់គ្រងកូតានេះជាសមត្ថកិច្ចរបស់អាជ្ញាធរអប្សរា ។ ក្នុងការអនុវត្តភារកិច្ចនេះ មានតែអាជ្ញាធរអប្សរាមួយគត់ដែលមានសិទ្ធិចេញលិខិតអនុញ្ញាតឱ្យ ចេញ-ចូល រមណីយដ្ឋានអង្គរដោយឥតបង់ថ្លៃ ។

**ប្រការ២ :** មូលហេតុដើម្បីទទួលបានការអនុញ្ញាតឱ្យ ចេញ-ចូល រមណីយដ្ឋានអង្គរដោយឥតបង់ថ្លៃមានដូចតទៅ ÷

<u>លក្ខណៈវិនិច្ឆ័យសំរាប់ទទួលការអនុញ្ញាតឱ្យ ចេញ-ចូល រមណីយដ្ឋានអង្គរដោយឥតបង់ថ្លៃ</u> :

១- រាល់លិខិតស្នើសុំត្រូវបញ្ជាក់ពីមូលហេតុដូចតទៅ :

- ទស្សនកិច្ចជាផ្លូវការដែលរៀបចំឡើងដោយរាជរដ្ឋាភិបាលសំរាប់គណៈប្រតិភូផ្លូវការ.
- បទយកការណ៍ជាផ្លូវការនិងកិច្ចសហប្រតិបត្តិការទីផ្សារទេសចរណ៍តាមរយៈការជួយជាផ្លូវការពីបរទេសសំរាប់ការផ្សព្វផ្សាយអំពីរមណីយដ្ឋានអង្គរដែលរៀបចំដោយក្រសួងទេសចរណ៍ឬអាជ្ញាធរអប្សរា ។
- ការសិក្សាស្រាវជ្រាវអំពីបុរាណវិទ្យានិងវប្បធម៌ដែលទទួលបានការយល់ព្រមពីក្រសួងវប្បធម៌ ឬពីអាជ្ញាធរអប្សរា ។

២- ការអនុញ្ញាតឱ្យ ចេញ-ចូល រមណីយដ្ឋានអង្គរដោយឥតបង់ថ្លៃមិនត្រូវឱ្យលើសពី០២ថ្ងៃឡើយ ។

៣- យោងសារាចរលេខ ២៤៩ ស.ជ.ណ អ វ ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ១៩៩៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី. គណៈប្រតិភូស្ថានទូត អង្គការអន្តរជាតិ អ្នកកាសែត និងអង្គការមិនមែនរដ្ឋាភិបាល មិនទទួលបានការអនុញ្ញាតឱ្យ ចេញ-ចូល រមណីយដ្ឋានអង្គរដោយឥតបង់ថ្លៃឡើយ ។

៤- ប័ណ្ណសំគាល់ខ្លួនចូលរមណីយដ្ឋានអង្គរដែលមានរយៈពេល៦ខែ និង១ឆ្នាំ គឺសំរាប់ផ្តល់ឱ្យតែអ្នកស្រាវជ្រាវវិស័យវប្បធម៌ដែលធ្វើការនៅក្នុងរមណីយដ្ឋានអង្គរតែប៉ុណ្ណោះ ។

<u>នីតិវិធីសំរាប់ទទួលការអនុញ្ញាតឱ្យ ចេញ-ចូល រមណីយដ្ឋានអង្គរដោយឥតបង់ថ្លៃ</u> :

១- រាល់លិខិតស្នើសុំ ត្រូវផ្ញើមកអាជ្ញាធរអប្សរាតាមរយៈក្រសួងនិងស្ថាប័នពាក់ព័ន្ធ ហើយលិខិតស្នើសុំទាំងនោះត្រូវចុះហត្ថលេខាដោយ រដ្ឋមន្ត្រី រដ្ឋលេខាធិការឬមន្ត្រីជាន់ខ្ពស់ដែលទទួលបានសិទ្ធិចុះហត្ថលេខា

២- រាល់លិខិតស្នើសុំត្រូវផ្ញើមកអាជ្ញាធរអប្សរាយ៉ាងយឺតបំផុតឱ្យបានមុនថ្ងៃចូល០៣ថ្ងៃ ។ ហើយលិខិតស្នើសុំនេះត្រូវផ្ញើជូនឯកឧត្តមប្រធានអគ្គនាយកអាជ្ញាធរអប្សរា ហើយឯកសារចម្លងត្រូវផ្ញើជូននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ ។

៣- លិខិតស្នើសុំធ្វើដំណើរសំរាប់ការផ្សព្វផ្សាយអំពីរមណីយដ្ឋានដែលរៀបចំឡើងដោយភ្នាក់ងារទេសចរណ៍ចាំបាច់ត្រូវឆ្លងតាមរយៈក្រសួងទេសចរណ៍ ហើយលិខិតនេះត្រូវបញ្ជូនមកអាជ្ញាធរអប្សរាយ៉ាងហោចណាស់ឱ្យបានមុនថ្ងៃចូល១៥ថ្ងៃ ។

៤- រាល់លិខិតស្នើសុំត្រូវភ្ជាប់មកជាមួយជាចាំបាច់នូវបញ្ជីឈ្មោះភ្ញៀវ ។

ក្រៅពីមូលហេតុដូចបានបញ្ជាក់ខាងលើ គ្មានមូលហេតុអ្វីផ្សេងទៀតដែលអាចទទួលបានការអនុញ្ញាតឱ្យ ចេញ-ចូល រមណីយដ្ឋានអង្គរដោយឥតបង់ថ្លៃឡើយ ។

ប្រការ៣ : មូលហេតុដូចបានបញ្ជាក់ក្នុងប្រការ២សំរាប់អនុវត្តក្នុងកូតាដែលកំពុងប្រើប្រាស់ ។ ក្នុងករណីកូតាត្រូវបានប្រើប្រាស់អស់ រាល់លិខិតស្នើសុំត្រូវមានការយល់ព្រមជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ប្រការ៤ : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់ក្រសួងស្ថាប័ន ខេត្ត-ក្រុង និងអាជ្ញាធរដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរ (អាជ្ញាធរអប្សរា) ត្រូវទទួលបន្ទុកអនុវត្តសេចក្តីប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០០១

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន